ជូនចំពោះ មាតាបិតា ឬ អ្នកបីបាច់ថែរក្សា:

លិខិតនេះធ្វើឡើងសម្រាប់មាតាបិតា ដែលមានកូន ចុះឈ្មោះនៅក្នុងផ្ទះថែទាំកូនក្មេង ឬ
នៅក្នុងមជ្ឈមណ្ឌលថែទាំកូនក្មេង ។ បទបញ្ជាតម្រូវឱ្យយើងផ្តល់
កម្រៃម្ហូបអាហារឱ្យដល់កូនក្មេងដែលចុះឈ្មោះទាំងអស់ ។ សូមជួយយើងខ្ញុំក្នុងការអនុវត្តិតាមសេចក្តីតម្រូវ
របស់កម្មវិធីម្ហូបអាហារ សម្រាប់ថែទាំកូនក្មេង និងមនុស្សធំពេញវ័យ របស់ក្រសួងកសិកម្មសហរដ្ឋអាមេរិក
(CACFP) ដោយបំពេញពាក្យផលកម្រៃម្ហូបអាហារនេះ (Meal Benefit Form) ។

<u>សម្រាប់កូនក្មេងចុះឈ្មោះនៅក្នុងផ្ទះថែទាំកូនក្មេងក្នុងគ្រួសារក្នុងពេលថ្ងៃ:</u>
<u>កូនរបស់លោកអ្នកបានចុះឈ្មោះនៅផ្ទះរបស់</u>

ដែលជាអ្នកផ្តល់ការថែទាំកូនក្មេងតាមផ្ទះក្នុងពេលថ្ងៃកំរិតទី២(Tier II) ចូលរួមនៅក្នុងកម្មវិធីម្ហូបអាហារ
សម្រាប់ថែទាំកូនក្មេង និងមនុស្សធំពេញវ័យ របស់ក្រសួងកសិកម្មសហរដ្ឋអាមេរិក (CACFP)
តាមកិច្ចព្រមព្រៀងមួយ ជាមួយទីភ្នាក់ងាររបស់យើងនោះ ។ នៅក្រោមកិច្ចព្រមព្រៀងនេះ
អ្នកផ្តល់ការថែទាំកូនក្មេងតាមផ្ទះ ក្នុងពេលថ្ងៃរបស់លោកអ្នកនិងទទួលបានប្រាក់កម្រៃ សម្រាប់ម្ហូបអាហារ
ដែលយកទៅចិញ្ចឹមកូនលោកអ្នក ក្នុងពេលថែទាំកូនលោកអ្នក ។ ចំនួននៃប្រាក់កម្រៃ
ដែលអ្នកផ្តល់ការថែទាំកូនក្មេងតាមផ្ទះក្នុងពេលថ្ងៃ របស់លោកអ្នក និងទទួលបាននោះ ពឹងផ្អែកទៅលើ
ប្រាក់ចំណូលនៃគ្រួសាររបស់កូនក្មេងដែលគេថែទាំនោះ ។ សូមបំពេញពាក្យសុំផលកម្រៃម្ហូបអាហារ(Meal Benefit
Form) ដែលផ្ទាប់មកជាមួយគ្នានេះ ហើយផ្ញើរមកវិញ ឱ្យបានឆាប់រហ័ស ដែលអាចធ្វើទៅបាន ។
សូមកុំផ្ញើរពាក្យសុំផលកម្រៃម្ហូបអាហារនេះ(Meal Benefit Form) ទៅឱ្យអ្នកផ្តល់ការថែទាំកូន របស់លោកអ្នក
ទាល់តែសោះ ។

សម្រេចទៅលើទំហំនៃគ្រួសារ និងទៅលើប្រាក់ចំណូលនៃគ្រួសាររបស់លោកអ្នក អ្នកផ្តល់ការថែទាំកូនរបស់លោកអ្នក